17/05/2021



បានឃើញលិខិតក្រឹត្យលេខ ២៨ ព្រ.ត ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១.- ត្រូវលើកលែងទោសជាបណ្តាច់ដល់ទណ្ឌិតចំនួន ០១ នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលជាប់ទោស :

- ទណ្ឌិតឈ្មោះ ណៃ ណារ៉ុម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់មួយជីវិត តាមសាលក្រមលេខ ៣៥ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៨៧ របស់តុលាការតាកែវ ។

មាត្រា ២.- ត្រូវបន្ធូរបន្ថយទោសរយៈពេល ៦ខែ ដល់ទណ្ឌិតចំនួន ០១នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលជាប់ទោស :

- ទណ្ឌិតឈ្មោះ កែវ សុវណ្ណរ័ត្ន ដែលផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមសាលក្រមលេខ ០៣ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការតាកែវ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៤.- ទីស្តីការគណៈរដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ តុលាការតាកែវ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា ។

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៤០០/០៥៦

## យើង

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០

## ត្រាស់បង្គាប់

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើតក្របខណ្ឌមន្ត្រីក្រមការដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២._**

ក្របខណ្ឌមន្ត្រីក្រមការដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែក សំរាប់ក្របខណ្ឌមន្ត្រីក្រមការនេះស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាល សំរាប់បណ្តាក្រសួង-ស្ថាប័ននានា ។ ឯការចាត់តាំងរបស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង ស្ថាប័នសាមី ។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខណ្ឌ សំរាប់ធ្វើការងារក្រមការផ្សេងពីក្របខណ្ឌមន្ត្រីរាជការឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

មាត្រា ៣ ._

មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការមានឧបនិស្ស័យសំរាប់ជាជំនួយក្នុងការងារដល់មន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយអាចបំពេញមុខតំណែងដឹកនាំកំរិតមធ្យម ក្នុងអង្គភាពរដ្ឋបាល គតិយុត្ត សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និងសង្គមកិច្ចនៃរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ស្របតាមមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ របស់រដ្ឋ ។

មន្ត្រីក្នុងក្របខ័ណ្ឌនេះក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងនៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

## ជំពូកទី ២

## ឋានន្តរសក្តិ និង មុខតំណែង

មាត្រា ៤ ._

ក្របខ័ណ្ឌមន្ត្រីក្រមការមាន ៣ ឋានន្តរសក្តិ ៖

- នាយក្រមការ មាន ០៦ ថ្នាក់
- ក្រមការដើមខ្សែ មាន ១០ ថ្នាក់
- ក្រមការ មាន ១៤ ថ្នាក់ ។

មាត្រា ៥ ._

មន្ត្រីក្នុងឋានន្តរសក្តិនាយក្រមការ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

- ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល
- អនុប្រធានមន្ទីរនៅខេត្ត-ក្រុង
- មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ។

មន្ត្រីក្នុងឋានន្តរសក្តិក្រមការដើមខ្សែ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

- អនុប្រធានការិយាល័យ ក្នុងរដ្ឋបាលកណ្តាល
- ប្រធានការិយាល័យ នៃមន្ទីរនៅខេត្ត-ក្រុង
- មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ។

មន្ត្រីក្នុងឋានន្តរសក្តិក្រមការ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

. ៥.

- អនុប្រធានការិយាល័យ នៃមន្ទីរនៅខេត្ត-ក្រុង
- មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៦ ._**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង-ឬ ក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិតត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៧ ._**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយមានសញ្ញាប័ត្រទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី ២ + ២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សា ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំឡើងកំពស់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយដែលស្ថិតយ៉ាងតិចបំផុតក្នុងថ្នាក់ លេខ១១ របស់ក្របខ័ណ្ឌប្រភេទ គ និងមានអាយុយ៉ាងច្រើនបំផុត ៤០ ឆ្នាំ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រសមមូល និងមធ្យមសិក្សាប័ត្រភាគទី ២ + ២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សាអាចប្រឡងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតលក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤០ឆ្នាំ ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨._**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និង-ឬ ក្នុងចំណោមនិស្សិត មានឋានៈជាសិស្សមន្ត្រីក្រមការ ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ។

17/05/2021



មាត្រា ៩._

បន្ទាប់ពីការប្រឡងជ្រើសរើសរួច សិស្សមន្ត្រីក្រមការត្រូវបានចាត់អោយទៅបំពេញការងារតាមក្រសួង-ស្ថាប័ន ហើយត្រូវបានតែងតាំងជាមន្ត្រីក្រមការកម្មសិក្សា ដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីក្រមការកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោម ៖

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត

២- ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនពុំស្ថិតក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាន ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុនពុំស្ថិតក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាន ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីដែលចែងក្នុងចំណុច ទី១ និង ទី ២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការ ឬក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្ថែមដែលមានរយៈពេលអតិបរមា ត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង ៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុច ទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោលប្រសិនបើចេញមកពីនិស្សិត ឬមួយបញ្ជូនទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការដោយគិតបញ្ចូលរយៈពេលអតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង-ស្ថាប័នសាមី ដោយបញ្ជាក់មូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីក្រមការដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៥ នៃឋានន្តរស័ក្តិក្រមការ ។

មន្ត្រីក្រមការដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ល្មើសបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការរួចហើយ មន្ត្រីក្រមការទាំងនេះ អាចត្រូវបានតែងតាំង ក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា៥ ខាងលើស្របតាមឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួង-ស្ថាប័នសាមីតាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

**មាត្រា ១១ .-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការអាចផ្លាស់ប្តូរពីក្រសួង ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀត តាមការស្នើសុំរបស់សាមីខ្លួន ឬតាមតំរូវការ ការងារដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរនិងដោយមានការយល់ព្រម ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង-ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២ .-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២៦ និង មាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោមនេះ ៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- មានស្មារតីទទួលខុសត្រូវ
- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ
- មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ៣ ភាគ ៤ តាមវេនជ្រើសរើសនិង ១ភាគ ៤ តាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១៣ .-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់បន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ដែលស្រុះស្រួលជាមួយសន្ទស្សន៍ខ្ពស់បន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងឬក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១៤.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិក្រមការ ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយក្រមការ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិក្រមការដើមខ្សែ ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាងអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមី សំរាប់កាន់មុខតំណែងស្របតាម ឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

**មាត្រា ១៦ .-**

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវដាក់អោយចូលនិវត្តន៍នៅពេលដល់អាយុ ៥៨ ឆ្នាំ ។

ដោយឡែកមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការដែលបំរើការងារក្នុងក្រសួងអប់រំ យុវជន និងកីឡា ការចូលនិវត្តន៍ត្រូវបានរំកិលដល់អាយុ ៦០ ឆ្នាំ ដូចក្របខ័ណ្ឌគ្រូបង្រៀននៃក្រសួងអប់រំ យុវជន និងកីឡា ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

***

17/05/2021



**មាត្រា ១៧.**_

មន្ត្រីក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្រ និងសញ្ញាប័ត្រក្រោយបរិញ្ញាប័ត្រត្រូវបានតម្លើងថ្នាក់មួយថ្នាក់ ជាស្វ័យប្រវត្តិ ។

**មាត្រា ១៨.**_

សញ្ញាសក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីក្រមការ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩.**_

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីក្រមការត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២០.**_

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១.**_

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

**ពេជ្រ ប៊ុនធិន**

★★★

www.moj.gov.kh